# វិធីសាស្ត្រសាមញ្ញសម្រាប់កសិករធ្វើការសម្រិត សម្រាំងគ្រាប់ពូជឱ្យបានល្អ

*ដោយៈ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា*

## គុណវិបត្តិនៃការប្រើគ្រាប់ពូជមិនសុទ្ធ

ភាពសុទ្ធនៃគ្រាប់ពូជស្រូវ គឺជាកត្តាចាំបាច់បំផុត ដែលកសិករគ្រប់រូបត្រូវតែយកចិត្តទុកដាក់។ គ្រាប់ពូជមិនសុទ្ធបណ្ដាលឲ្យ៖

- បាត់បង់ផលពី១០% ទៅ ៣០%
- អង្ករកិនបានតិច និងបាក់ច្រើន
- អង្ករ និងស្រូវលក់បានក្នុងតម្លៃថោក
- បាយទន់ក្លាយជារឹង បាយក្រអូបក្លាយជាមិនក្រអូប
- បាយឆ្អិនមិនស្មើ និងឆាប់ផ្អូម
- សំណាបដុះមកមិនបានស្មើ និងជំជាត់ល្អដូចៗគ្នាទេ

### តើយើងត្រូវសម្រិតសម្រាំងគ្រាប់ពូជស្រូវយ៉ាងដូចម្ដេច?

កសិករអាចចាប់ផ្ដើមធ្វើការសម្រិតសម្រាំងគ្រាប់ពូជស្រូវរបស់ខ្លួនឯងជាជំហានៗដូចខាងក្រោម៖





*គ្រាប់ពូជសុទ្ធល្អ ផ្ដល់ផលច្រើន*





*គ្រាប់ពូជមិនសុទ្ធ ផ្ដល់ផលតិច*

**ជំហានទី ១៖** ត្រូវដឹងអំពីទំហំស្រែ និងបរិមាណគ្រាប់ពូជដែលត្រូវការ។ ឧទាហរណ៍ ស្រែទំហំ ១ ហិកតា និងត្រូវការគ្រាប់ពូជសម្រាប់ស្ទូង២០ - ៣០ គ.ក្រ។

**ជំហានទី ២៖** កំណត់នូវទំហំកូនស្រែសម្រាប់សម្រិតសម្រាំងគ្រាប់ពូជដែលត្រូវការដោយជ្រើសរើសទីតាំងក្នុងស្រែកន្លែងណាដែលស្រូវដុះបានល្អស្មើជាងគេកន្លងមក រួចបោះបង្គោលចងខ្សែព័ទ្ធជុំវិញលើផ្ទៃដីដែលអាចប្រមូលផលបានស្មើ ឬច្រើនជាងបរិមាណគ្រាប់ពូជត្រូវការបន្តិចបន្តួច។ ឧទាហរណ៍ ផលស្រូវប្រមូលក្នុង១ ហិកតា បាន៣.០០០ គ.ក្រ គឺក្នុង ១ អា បាន៣០ គ.ក្រ ដូច្នេះ កូនស្រែសម្រាប់សម្រិតសម្រាំងពូជគឺត្រូវមានទំហំយ៉ាងតូចបំផុត ១ អា។

**ជំហានទី ៣៖** កំណត់នូវបរិមាណគ្រាប់ពូជសម្រាប់ស្ទូងក្នុងកូនស្រែសម្រិតសម្រាំងគ្រាប់ពូជ។ យកគ្រាប់ពូជរក្សាទុក

សម្រាប់សាប ឬព្រោះមកអុំ រែង ស្ទៃ រើសយកតែគ្រាប់ពូជណាមានទំហំ និងព៌ណប្រហាក់ប្រហែលគ្នាឲ្យបានគ្រប់បរិមាណត្រូវការ។ ឧទាហរណ៍ សម្រាប់ស្ទូងស្រែ១ អា ត្រូវការគ្រាប់ពូជ ១ គ.ក្រ។

**ជំហានទី៤៖** ជ្រើសរើសដីថ្នាលសំណាប ដែលនៅជិតប្រភពទឹក ងាយទៅមើលថែទាំ និងឆ្ងាយពីពន្លឺភ្លើង ដោយកំណត់ផ្ទៃថ្នាល១០ ម² សម្រាប់គ្រាប់ពូជ ១ គ.ក្រ។ ត្រូវធ្វើដីឲ្យបានស្អាតល្អកុំឲ្យមានស្មៅ និងជាពិសេសគ្រាប់ស្រូវដុះពីរដូវមុនដុះលាយឡំ។ ចូរថែទាំសំណាបឲ្យបានល្អ។

**ជំហានទី៥៖** ត្រូវធ្វើដីកូនស្រែសម្រិតសម្រាំងគ្រាប់ពូជឲ្យបានស្អាត និងរាបស្មើល្អ។ ស្ទូងសំណាបជាជួរ ឬឲ្យបានរៀងជាជួរចំនួន២-៣ ដើមក្នុង១ គុម្ព។ ការស្ទូងជាជួរជាការសំខាន់ណាស់សម្រាប់ការងារសម្រិតសម្រាំងគ្រាប់ពូជស្រូវ។ ចូរដាក់ទឹក ធ្វើស្មៅ ដាក់ជីទ្រាប់បាត និងបំប៉ន ព្រមទាំងថែទាំឲ្យស្រូវដុះលូតលាស់បានល្អ និងបានផលច្រើន។

**ជំហានទី ៦៖** បន្ទាប់ពីសន្ទូងដុះលូតលាស់បានល្អមកត្រូវដើរកាត់ ឬដកគុម្ពស្រូវណា ដែលមានលក្ខណៈខុសគេចោលយ៉ាងហោចណាស់ចំនួន ៣ ដំណាក់កាលដូចខាងក្រោម៖

ដំណាក់កាលទី ១ ត្រូវធ្វើនៅពេលស្រូវបែកគុម្ពបន្ទាប់ពីស្ទូងរួចបាន២០-៣០ ថ្ងៃ ដោយត្រូវដើរដកគុម្ពស្រូវណាដែលដុះខុសជួរ និងមានលក្ខណៈខុសគេចោល។

ដំណាក់កាលទី២ ត្រូវធ្វើនៅពេលស្រូវហាលផ្កា។ គុម្ពស្រូវណាចេញផ្កាយឺត ឬលឿនជាងគេប្រហែល ៣-៥ ថ្ងៃ ទម្រង់ និងពណ៌ គ្រាប់ និងកួរស្រូវខុសគេ ត្រូវកាត់ចោលឲ្យដល់គល់។

ដំណាក់កាលទី៣ ត្រូវធ្វើនៅពេលស្រូវទុំស្លាបសេកដោយកាត់គុម្ពស្រូវណាមានជំងឺ សណ្ឋានកួរ ព្រមទាំងគ្រាប់មានកន្ទុយពណ៌ប្រវែង និងទំហំខុសគេចោល។

**ជំហានទី៧៖** ត្រូវប្រមូលផលស្រូវនៅពេលគ្រាប់ទុំល្អគឺនៅពេលដែលកួរស្រូវយ៉ាងហោចណាស់៩០% មានគ្រាប់ចាប់ពីពាក់កណ្ដាលកួរខាងលើពណ៌លឿងទុំចាស់ និងគ្រាប់ពេញពាក់កណ្ដាលកួរខាងក្រោមពណ៌លឿងទុំស្រាល ហើយគ្រាប់ស្អកពណ៌ស្លាបសេកចាស់។

**ជំហានទី៨៖** ត្រូវបោក ឬបែនដាច់ដោយឡែកពីគេ និងដោយប្រយ័ត្នប្រយែងបំផុត ព្រមទាំងអុំ និងរោយឲ្យបានល្អ។

**ជំហានទី៩៖** ហាលសម្ងួតគ្រាប់ពូជស្រូវ នៅលើកន្ទេលសំណាញ់ មុង និងតង់កៅស៊ូក្នុងកម្រាស់គ្រាប់ស្រូវ ២-៣ ស.ម និងឧស្សាហ៍ដាប្រចាំរហូតស្ងួតល្អ រួចអុំ និងរោយសម្អាតឲ្យបានស្អាតល្អកុំឲ្យមានគ្រាប់ស្មៀតគ្រាប់ស្មៅ និងកំទេចកំទីផ្សេងៗនៅលាយឡំ។

**ជំហានទី ១០៖** គ្រាប់ពូជស្រូវ ត្រូវច្រកទុកនៅក្នុងថង់ប្លាស្ទិកចងមាត់ឲ្យជិត កុំឲ្យមានខ្យល់ រួចដាក់ក្នុងបាវមួយជាន់ទៀត ហើយទុកដាក់ដាច់ដោយឡែកពីគ្រាប់ស្រូវចំណី នៅកន្លែងដែលស្ងួតល្អ និងគ្មានការបំផ្លាញពីសត្វកណ្ដុរ មាន់ ទាជាដើម។ ត្រូវសរសេរឈ្មោះពូជ និងថ្ងៃខែច្រូតកាត់ ដាក់នៅលើបាវឲ្យបានត្រឹមត្រូវល្អ។

ស្រែមានទំហំ = ១ ហិកតា
ផលបានជាមធ្យម= ៣.០០០ គ.ក្រ ឬ ៣០គ.ក្រ/១អា
គ្រាប់ពូជត្រូវការសម្រាប់ស្ទូង = ២០ ទៅ ៣០ គ.ក្រ/ហិកតា

កូនស្រែសម្រិតសម្រាំងគ្រាប់ពូជ = ១ អា
(១០ ម X ១០ ម ឬ ៥ ម X ២០ ម)
បរិមាណគ្រាប់ពូជសម្រាប់ស្ទូងយ៉ាងច្រើនបំផុត = ១ គ.ក្រ




